CITY OF LONG BEACH

# PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 24 ខែឧសភា ឆ្នាំ 2021
ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងឡុងប៊ិច, 562.570.NEWS (6397),
jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# ការបិទដំណើរការ នៅថ្ងៃទិវារំឭកការចងចាំ នៃទីក្រុងឡុងប៊ិច

## *រំឭកពីការអបអរសាទរដោយសុវត្ថិភាព និងអនុវត្តរាល់ពិធីសារសុវត្ថិភាព និងសុខាភិបាលទាំងអស់ នៅពេលឈប់សម្រាកចុងសប្តាហ៍*

ឡុងប៊ិច, CA - បន្ថែមលើការបិទសម្បទា និងសេវានានា របស់ទីក្រុងឡុងប៊ិច ដើម្បីប្រារព្ធ ទិវារំឭកការចងចាំ នៅថ្ងៃទី 31 ខែឧសភា ឆ្នាំ 2021 សាលាក្រុងក៏សូមដាស់តឿន ប្រជាពលរដ្ឋ និងភ្ញៀវ របស់ឡុងប៊ិច ឱ្យអនុវត្តពិធីសារសុវត្ថិភាព និងសុខាភិបាល ទាំងអស់ នៅពេលឈប់សម្រាកចុងសប្តាហ៍ ដើម្បីរក្សាឱ្យសហគមន៍របស់យើង មានសុវត្ថិភាព និងរួចផុតពីការកើនឡើង នៃករណីឆ្លង COVID-19 ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Mayor Robert Garcia) «ខណៈដែលមានច្រើនកន្លែង បានបើកដំណើរការឡើងវិញ ហើយយើងកំពុងត្រឡប់ ទៅរកប្រក្រតីភាពថ្មីមួយទៀតនោះ, ជាការសំខាន់ ដែលប្រជាពលរដ្ឋបន្តអនុវត្ត វិធានការសុវត្ថិភាព សមស្រប នៅពេលរីករាយ នឹងការឈប់សម្រាក នៅចុងសប្តាហ៍ ។» «យើងខ្ញុំលើកទឹកចិត្តប្រជាពលរដ្ឋ ឱ្យរីករាយនឹងសកម្មភាព នៅទីវាល រក្សាគម្លាតរាងកាយ ពីក្រុមផ្សេងៗទៀត និងដោយពាក់របាំងមុខ ។»

**សុខភាព និងសុវត្ថិភាព COVID-19**
សាលាក្រុងសូមដាស់តឿនអ្នកគ្រប់គ្នា ឱ្យរក្សាការប្រុងប្រយ័ត្ន ក្នុងការអនុវត្ត ពិធីសារសុវត្ថិភាព និងសុខាភិបាល ទាំងអស់ ដូចមានបញ្ជាក់ នៅក្នុង បទបញ្ជាសុខាភិបាល ឱ្យនៅផ្ទះមានសុវត្ថិភាពជាង ។ អនុលោមតាមគោលការណ៍ណែនាំរបស់រដ្ឋ ប្រជាពលរដ្ឋត្រូវបានលើកទឹកចិត្តឱ្យ ចូលរួម ក្នុងការជួបជុំគ្នា នៅទីវាល ជាជាង នៅក្នុងអគារ, រក្សាគម្លាតសមស្រប ពីគ្នា, និងគួរបន្តពាក់ម៉ាស់ សមល្មមនឹងមុខ នៅពេលចេញទៅទីសាធារណៈ និងនៅក្នុងអគារ ទោះបីជាបានចាក់វ៉ាក់សាំងរួចរាល់ហើយក្តី ។

**សុវត្ថិភាពកាំជ្រួច**
មិនត្រឹមតែ កាំជ្រួចលក្ខណៈបុគ្គលទាំងអស់នោះទេ វារួមបញ្ចូល ទាំងកាំជ្រួច មានស្លាក «សុវត្ថិភាព និងត្រឹមត្រូវ» ផងដែរ ដែលត្រូវបានហាមឃាត់ នៅក្នុងទីក្រុងឡុងប៊ិច ប៉ុន្តែវាក៏ជាគ្រោះថ្នាក់ផងដែរ សម្រាប់ប្រជាពលរដ្ឋ និងសំណង់ ដែលនៅក្បែរ ដោយធ្វើឱ្យមានការខូចខាតទ្រព្យសម្បត្តិ អស់ដប់លានដុល្លារ ជារៀងរាល់ឆ្នាំ និងបង្ករឱ្យមានរបួសស្នាមជាច្រើន ដែលភាគច្រើន កុមារជាជនរងគ្រោះ ។ សម្លេងកាំជ្រួចឮខ្លាំងៗ ដោយមិនបានរំពឹងទុក ក៏បានបង្ករឱ្យមាន ហានិភ័យ ផ្នែកសុខភាព ធ្ងន់ធ្ងរ សម្រាប់អតីតយុទ្ធជន និងប្រជាពលរដ្ឋផ្សេងទៀត ដែលមានបញ្ហាភាពតានតឹងចិត្ត ក្រោយបានឆ្លងកាត់វិបត្តិ ហើយធ្វើឱ្យសត្វចិញ្ចឹមជាច្រើន ផ្អើលភ័យរន្ធត់ផងដែរ ។

ដើម្បីរាយការណ៍ អំពីសកម្មភាពបាញ់កាំជ្រួច ដោយខុសច្បាប់ ដែលកើតមាន នៅឡុងប៊ិច, ប្រជាពលរដ្ឋអាចអនុវត្តតាម វិធីណាមួយ ដូចខាងក្រោមនេះ ។ សម្រាប់ករណីអាសន្ន សូមទូរសព្ទទៅលេខ 9-1-1 ជានិច្ច ។

- សូមដាក់ពាក្យបណ្តឹង ឬ បញ្ជូល រូបភាព និងវីដេអូ បង្ហាញពីសកម្មភាពបាញ់កាំជ្រួច ខុសច្បាប់ ជូនទៅការិយាល័យរដ្ឋអាជ្ញាក្រុង ។
- សូមទូរសព្ទ ទៅលេខមិនមែនសម្រាប់ករណីអាសន្ន នៅមជ្ឈមណ្ឌលគមនាគមន៍ គឺ 562.435.6711 ដើម្បីរាយការណ៍ អំពីការប្រើប្រាស់ និង/ឬ ការលក់កាំជ្រួច ។
- សូមផ្ញើអ៊ីមែលទៅ ផ្នែកល្បាតមើល អំពីទីកន្លែង ដែលសកម្មភាព បែបនេះ កើតមានឡើង និងផ្តល់អាសយដ្ឋាន, វីដេអូ, ផ្លាកលេខ, រូបថត និងព័ត៌មានផ្សេងៗ ទៀត ដែលអាចប្រើប្រាស់បានសម្រាប់ការស៊ើបអង្កេត ។ សូមរួមបញ្ចូលឈ្មោះ អាសយដ្ឋាន និងលេខទូរសព្ទ របស់លោកអ្នក ដើម្បីឱ្យគេអាចទាក់ទង ទៅលោកអ្នកបាន តាមការចាំបាច់ ៖
    - LBPDNorth@longbeach.gov
    - LBPDSouth@longbeach.gov
    - LBPDEast@longbeach.gov
    - LBPDWest@longbeach.gov

**សម្បទា និងសេវានានារបស់សាលាក្រុងដែលបានចុះបញ្ជីដូចកាលវិភាគខាងក្រោមនេះអំឡុងពេលទិវារំឭកការចងចាំ។**

**បើកដំណើរការ នៅថ្ងៃចន្ទ ទី 31 ខែឧសភា ក្នុងអំឡុងម៉ោងធ្វើការ ធម្មតា ៖**

- ស្ថានីយអគ្គីភ័យ និងស្ថានីយសង្គ្រោះជីវិត (Lifeguard)
- ឧទ្យាន និងផ្លូវទាំងអស់ ក្នុងទីក្រុង
- អាកាសយានដ្ឋាន ឡុងប៊ិច
- ឧទ្យានតំបន់ អ៊ែល ដូរ៉ាដូ (El Dorado) (មជ្ឈមណ្ឌលធម្មជាតិ អ៊ែល ដូរ៉ាដូ បិទមិនដំណើរការ)
- ការិយាល័យផែសមុទ្រ (ផែឆកសមុទ្រ អាឡាមីថូស, ផែសមុទ្រ សរឡាញ)*
- តុទទួលភ្ញៀវ នៅស្ថានីយនគរបាលចំបង
- ទីតាំងប្រមូលសំណល់ និងកែច្នៃឡើងវិញ
- ក្រុមសេវាឧស្ម័ន (562.570.2140) បើកដំណើរការ 24/7 សម្រាប់ការទូរសព្ទចូល រាយការណ៍ អំពីករណីអាសន្ន
- ក្រុមសេវាទឹកស្អាត/លូ (562.570.2390) បើកដំណើរការ 24/7 សម្រាប់ការហៅអាសន្ន

**បិទដំណើរការ នៅថ្ងៃចន្ទ ទី 31 ខែឧសភា ៖**

- មជ្ឈមណ្ឌលព័ត៌មានរួម (562.570.NEWS), បណ្តាញលេខទាន់ហេតុការណ៍ ផ្នែកសហគមន៍ (562.570.INFO), បណ្តាញលេខទាន់ហេតុការណ៍ ផ្នែកជនជាន (562.570.INFO, ជម្រើស [option] 5), បណ្តាញលេខទាន់ហេតុការណ៍ ផ្នែកធុរកិច្ច (562.570.4BIZ)
- ទីតាំងធ្វើតេស្ត និងចាក់វ៉ាក់សាំង COVID-19 ទាំងអស់ ដែលប្រតិបត្តិការ ដោយសាលាក្រុង
- សេវាថែទាំសត្វ និង spcaLA*
- បណ្ណាល័យចំបង ប៊ីលលី ជែន ឃីង (Billie Jean King Main Library), សាខាទាំងអស់ របស់បណ្ណាល័យ រួមទាំងសេវាមកយក LBPL To-Go និងការិយាល័យបណ្ណាល័យ (មានធនធានឌីជីថល ផ្តល់ជូន 24/7)

- កន្លែងការងារ, មជ្ឈមណ្ឌលឱកាសយុវជន និង ការិយាល័យរដ្ឋបាល* របស់ច្រកប៉ាស៊ីហ្វិក (Pacific Gateway)
- អគារសាលាក្រុង*
- គណៈកម្មការបណ្តឹងនគរបាល សម្រាប់ពលរដ្ឋ
- សេវាសាងសង់ និងសុវត្ថិភាព រួមទាំង អធិការកិច្ច, សេវាពិនិត្យប្លង់ និងមជ្ឈមណ្ឌលផ្តល់លិខិតអនុញ្ញាត*
- សេវាអនុវត្តក្រមច្បាប់ រួមទាំង កងកម្លាំងនៅតាមទីតាំង COVID-19
- ការិយាល័យធនធានថាមពល
- ទីបញ្ជាការអគ្គីភ័យ, សេវាគាំទ្រ, អង្គភាពបង្ការ និងប្រតិបត្តិការ អគ្គីភ័យ រួមទាំង រដ្ឋបាលសុវត្ថិភាពសមុទ្រ
- នាយកដ្ឋានសុខាភិបាល និងសម្បទាសុខាភិបាល*
- អាជ្ញាធរលំនៅដ្ឋាន*
- ការិយាល័យរដ្ឋបាល នៃអាកាសយានដ្ឋាន ឡុងប៊ិច
- មជ្ឈមណ្ឌលធនធានភូមិស្ថាន*
- ការិយាល័យឧទ្យាន និងសម្បទាឧទ្យានសហគមន៍*
- ព្រឹត្តិការណ៍ពិសេសៗ និងព្រឹត្តិការណ៍ភាពយន្ត
- ការបោសសម្អាតផ្លូវថ្នល់
- អាងហែលទឹក
- ការអូសសណ្តោងយានយន្ត និងការលក់លៃឡុង
- ការិយាល័យនានារបស់នាយកដ្ឋានទឹក
- មជ្ឈមណ្ឌលឧស្ម័ន, ទឹក និងប្រមូលសំណល់

* បង្ហាញ សម្បទា និងសេវា របស់សាលាក្រុង ដែលកំពុងដំណើរការ ក្រោមប្រតិបត្តិការ កែសម្រួល នាពេលបច្ចុប្បន្ននេះ រហូតដល់ពេលមានសេចក្តីជូនដំណឹង បន្ថែមទៀត ដោយសារការដាក់កំហិត ផ្នែកសុខភាពសាធារណៈ បណ្តាលមកពី COVID-19 ។

**សាលាក្រុង**
សាលាក្រុងនៅតែបិទមិនឱ្យសាធារណជនចូល រហូតទាល់តែមានសេចក្តីជូនដំណឹងបន្ថែមទៀត លើកលែងតែការណាត់ជួប ទុកជាមុន សម្រាប់មជ្ឈមណ្ឌលផ្តល់លិខិតអនុញ្ញាត ។ ប្រជាពលរដ្ឋត្រូវបានលើកទឹកចិត្ត ឱ្យប្រើប្រាស់សេវាតាមអ៊ីនធឺណែត ក្នុងអំឡុងពេលនេះ ។

**ការបោសសម្អាតផ្លូវថ្នល់**
នឹងគ្មានកាលវិភាគកំណត់ សម្រាប់ការបោសសម្អាតថ្នល់ ឬ ការអនុវត្តច្បាប់ ចំពោះការរំលោភបំពានលើការបោសសម្អាតថ្នល់ នៅថ្ងៃចន្ទ ទី 31 ខែឧសភា នោះទេ ។ ការបោសសម្អាតថ្នល់ នឹងចាប់ដំណើរការឡើងវិញ ជាធម្មតា តាមកាលវិភាគកំណត់ នៅថ្ងៃអង្គារ ទី 1 ខែមិថុនា ។

**ការអនុវត្ត លើការចតយានជំនិះ**
មើល កុងទ័រចំណត របស់លោកអ្នក ៖ កុងទ័រទីចំណត នឹងត្រូវដាក់ឱ្យអនុវត្ត នៅថ្ងៃចន្ទ ទី 31 ខែឧសភា លុះណាតែកុងទ័រ បង្ហាញ «លើកលែង នៅថ្ងៃឈប់សម្រាក» ។ ថ្ងៃ និងម៉ោងនៃការអនុវត្ត មានបង្ហាញជូន នៅខាងក្នុង កុងទ័រ ។

**សំណល់/ការកែច្នៃឡើងវិញ**
សម្រាម និងគ្រឿងកែច្នៃឡើងវិញ នឹងត្រូវប្រមូល តាមកាលវិភាគកំណត់ នៅថ្ងៃចន្ទ ទី 31 ខែឧសភា ។

**ការអូសសណ្តោងយានយន្ត និងការលក់លៃឡុង**
ប្រតិបត្តិការសណ្តោង និងសម្បទារក្សាទុកយានជំនិះ ដែលមានអាសយដ្ឋានលេខ 3111 វិថី អ៊ី វិលឡូវ (E. Willow St.) នៅចន្លោះរុក្ខវិថីថែមផល (Temple Avenue) និងរុក្ខវិថីរ៉េនដុនដូ (Redondo Avenue) នឹងបិទ នៅថ្ងៃចន្ទ ទី 31 ខែឧសភា ។ ម៉ោងដំណើរការ ធម្មតាគឺ ៖

- ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច
- ថ្ងៃថ្ងៃសៅរ៍ 8 ព្រឹក ដល់ម៉ោង 4 ល្ងាច
- បិទដំណើរការ នៅថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាក

យានជំនិះ និងទីតាំង នៅក្រៅម៉ោងមានបញ្ជាក់រួចខាងលើនេះ អាចរកបាន ដោយមានគិតប្រាក់បន្ថែម ។ ព័ត៌មាន បន្ថែមទៀត អាចរកបាន នៅលើអ៊ីនធឺណែត។

**បណ្ណាល័យ**
នៅថ្ងៃទី 18 ខែឧសភា ឆ្នាំ 2021, បណ្ណាល័យចំបង BJK, ប៉េយ៍ ស (Bay Shore), ម៉ាក ត្វេន (Mark Twain) និងបណ្ណាល័យភូមិស្ថាន មីស៊ែល អូបាម៉ា បានបើកដំណើរការបម្រើជូនសាធារណជន ឡើងវិញ ដោយមានសេវា និងសមត្ថភាពទទួល ក្នុងដែនកម្រិតមួយ ។ សេវា LBPL To-Go នៅមានបម្រើជូន នៅតាមទីតាំង LBPL ដែលបានបើកដំណើរការឡើងវិញ ព្រមទាំងនៅ បណ្ណាល័យភូមិស្ថាន ប្រ៊េត ហាត (Bret Harte), អ៊ែល ដូរ៉ាដូ (El Dorado) និង ឡូស អាល់តូស (Los Altos) ផងដែរ ។ ទីតាំង LBPL ចំនួនប្រាំកន្លែង, បណ្ណាល័យភូមិស្ថាន អាឡាមីតូស (Alamitos), បាជ (Bach), ប្រ៊ូវីត (Brewitt), ប៊ើននែត (Burnett) និងដាណា (Dana) នៅតែបិទ មិនបម្រើជូនសាធារណជនដដែល នៅពេលនេះ ។

ដើម្បីប្រារព្ធ ទិវារំឭកការចងចាំ, ទីតាំងបណ្ណាល័យទាំងអស់ និងសេវានានា រួមទាំង បណ្តាញទូរសព្ទចំបងរបស់បណ្ណាល័យ នឹងបិទមិនបម្រើការទេ នៅថ្ងៃសៅរ៍ ទី 29 ខែឧសភា ។ អ្នកប្រើប្រាស់បណ្ណាល័យ ត្រូវបានលើកទឹកចិត្ត ឱ្យប្រើប្រាស់ កម្រង ធនធានឌីជីថល យ៉ាងច្រើនអនេក របស់ LBPL រួមទាំង កាតាឡុក, ឯកសារសម្រាប់ទាញយក, និងទិន្នន្នដ្ឋាន របស់បណ្ណាល័យ ដែលមានបម្រើជូន 24/7 ។

សម្រាប់ព័ត៌មានចុងក្រោយបំផុត អំពី COVID-19 ដែលមានសេចក្តីលំអិត អំពីសកម្មភាពទាំងអស់របស់សាលាក្រុងឡុងប៊ិច ក្នុងការរក្សាសុវត្ថិភាព របស់ប្រជាពលរដ្ឋរបស់យើង សូមចូលទៅ long-beach.gov/COVID19 ហើយតាម @LongBeachCity នៅលើ Facebook, Twitter និង Instagram ។

# # #